ក **N°29/16**→*19/4/2016*

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ១១-៤-២០១៦ | -ព្រះរាជក្រម នស/រកម/០៤១៦/០០៦ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី គណនេយ្យ និងសវនកម្ម | ៣២៩៧ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៤-៤-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៧២ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម ចំនួន ០៥រូប | ៣៣១២ |
| ០៤-៤-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៧៣ ស្តីពី លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | ៣៣១៣ |
| ០៤-៤-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៧៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ ឧកញ៉ា **លី ឆេង** | ៣៣៣២ |


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ០៦-៤-២០១៦ | -អនុក្រឹត្យលេខ ៦១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៣៣៣៣ |
| ២៨-៣-២០១៦ | -អនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៣៣៣៥ |
| ២៨-៣-២០១៦ | -អនុក្រឹត្យលេខ ៣៤៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៣៣៤០ |
| ២៨-៣-២០១៦ | -អនុក្រឹត្យលេខ ៣៤៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៣៣៤៥ |
| ២៨-៣-២០១៦ | -អនុក្រឹត្យលេខ ៣៥០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣៣៥២ |
| ២៨-៣-២០១៦ | -អនុក្រឹត្យលេខ ៣៥១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៣៣៥៣ |
| ២៩-៣-២០១៦ | -អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣៣៥៤ |
| ២៩-៣-២០១៦ | -អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៣៣៥៥ |
| ២៩-៣-២០១៦ | -អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី | ៣៣៥៧ |
| ២៩-៣-២០១៦ | -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី | ៣៣៥៨ |

២៩-៣-២០១៦ -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៣៣៦០
២៩-៣-២០១៦ -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៣៣៦១
២៩-៣-២០១៦ -អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៣៣៦២
២៩-៣-២០១៦ -អនុក្រឹត្យលេខ ៣៥៩ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៣៣៦៤
២៩-៣-២០១៦ -អនុក្រឹត្យលេខ ៣៦០ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៣៣៦៥

## ២-សេចក្ដីសម្រេច

០៥-៤-២០១៦ -សេចក្ដីសម្រេចលេខ ៣២ សសរ ស្ដីពី ការកែសម្រួលរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ៣៣៦៦
០៨-៤-២០១៦ -សេចក្ដីសម្រេចលេខ ៣៣ សសរ ស្ដីពី ការបំពេញបន្ថែម និងផ្លាស់ប្ដូរសមាជិកក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៣៣៦៨

## ៣-សារាចរ

០៦-៤-២០១៦ -សារាចរលេខ ០៥ សរ ស្ដីពី ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១៣០ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៦ ៣៣៧០

## ៤-សារាចរណែនាំ

១៩-៤-២០១៦ -សារាចរណែនាំលេខ ០២ សរណន ស្ដីពី ការគ្រប់គ្រងរថយន្តនាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ និងការកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ៣៣៧២

## III-ការងារបណ្ដាក្រសួង

## ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៩-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១៧៥ សហវ.ហក ស្ដីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៦ របស់ក្រសួងផែនការ ៣៣៧៥
២៩-០២-២០១៦ -ប្រកាសលេខ ១៧៧ សហវ.ប្រក ស្ដីពី ការបង្កើត និងតែងតាំងក្រុមលទ្ធកម្មរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តឧត្តរមានជ័យ ៣៣៨០
០១-៣-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១៧៨ សហវ.ប្រក ស្ដីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៦ របស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ៣៣៨៣

២៩-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១៧៩ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន នៅទីស្តីការគណៈរដ្ឋមន្ត្រី ៣៣៨៧

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

៣១-១២-២០១៥-ប្រកាសលេខ ៧៥១ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូកាតូ (ខេមបូឌា) ភ្នំពេញ បង្កើតរោងចក្រ ផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះ (ក្រណាត់ទ្រនាប់ចានបង្គន់ អំបោស និងច្រាស) ៣៣៩៦

៣១-១២-២០១៥-ប្រកាសលេខ ៧៥២ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ណាកាយ៉ាម៉ា (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៣៩៩

៣១-១២-២០១៥-ប្រកាសលេខ ៧៥៣ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ារូ ឈុន (ខេមបូឌា) ខប អិលធីឌី បង្កើតរោងចក្រ ផលិតស្បែកជើង ៣៤០២

៣១-១២-២០១៥-ប្រកាសលេខ ៧៥៤ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន ហុងកុង ហ្គោលដេន អាត អ៊ិនដាសស្ទ្រៀល បង្កើតរោងចក្រ ផលិតផ្កាសិប្បនិម្មិត ៣៤០៥

៣១-១២-២០១៥-ប្រកាសលេខ ៧៥៥ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហារ៉ុ ភ្នំពេញ កូមីក សេនធ័រ បង្កើតរោងចក្រ ផលិតសៀវភៅអាន ៣៤០៨

៣១-១២-២០១៥-ប្រកាសលេខ ៧៥៦ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តៃណាន អេនធើប្រាយ បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៤១១

៣១-១២-២០១៥-ប្រកាសលេខ ៧៥៧ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ័រម៉ាត (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣៤១៤

# ព្រះរាជក្រម

នស/រកម/០៤១៦/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែចំណុចគ្រែទី៤ នៃមាត្រា៧ ក្នុងសេចក្តីសម្រេចលេខ១៥៩/០០១/២០១៦ កបធ.ច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពី
# គណនេយ្យ និងសវនកម្ម

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងគ្រប់គ្រងវិស័យគណនេយ្យ និងសវនកម្មប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាននៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅ ៖

- កំណត់ក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងគណនេយ្យ និងសវនកម្ម
- ពង្រឹង និងអភិវឌ្ឍសមត្ថភាពស្ថាប័នសម្រាប់ការគ្រប់គ្រងគណនេយ្យ និងសវនកម្ម
- ពង្រឹង និងអភិវឌ្ឍសមត្ថភាពជំនាញ និងការទទួលខុសត្រូវរបស់គណនេយ្យករ និងសវនករ
- កំណត់ក្របខ័ណ្ឌគតិយុត្តសម្រាប់ការដាក់ឲ្យអនុវត្តស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងក្រមសីលធម៌វិជ្ជាជីវៈរបស់គណនេយ្យករ និងសវនករដែលជាគោលការណ៍ត្រូវមានសង្គតិភាពជាមួយនឹងស្តង់ដាអន្តរជាតិ និងត្រូវឆ្លុះបញ្ចាំងសេចក្តីត្រូវការជាក់ស្តែងរបស់កម្ពុជា
- ដាក់ចេញនូវយន្តការវិធាន និងនីតិវិធីសម្រាប់ការតាមដានការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តច្បាប់នេះ
- ពង្រឹង និងអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះស្ថាប័នសាធារណៈ សហគ្រាសអង្គភាពមិនស្វែងរកប្រាក់ចំណេញគណនេយ្យករ និងសវនករ ។

ច្បាប់នេះមិនអនុវត្តចំពោះធនាគារកណ្តាល និងចំពោះតួនាទី និងភារកិច្ចដែលជាសមត្ថកិច្ចរបស់អាជ្ញាធរសវនកម្មជាតិទេ ។

**មាត្រា ៤.-**

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចបានកំណត់ក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

# ជំពូកទី ២
# ក្រុមប្រឹក្សាជាតិគណនេយ្យ

**មាត្រា ៥.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិគណនេយ្យ ដែលសរសេរជាអក្សរកាត់ថា **ក.ជ.គ.**ស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សមាសភាព **ក.ជ.គ.**មានអាណត្តិកំណត់រយៈពេល ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ចនៅមុនពេលផុតអាណត្តិទៅតាមការចាំបាច់នៃមុខងារ ។ សមាសភាព **ក.ជ.គ.**អាចបន្តអាណត្តិសាជាថ្មីបានតាមសំណើរបស់ប្រធាន **ក.ជ.គ.** ។

**មាត្រា ៦.-**

**ក.ជ.គ.**មានសមាសភាពដូចខាងក្រោម ៖

១- រដ្ឋមន្ត្រី ឬតំណាងជាឥស្សរជនជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

| | | |
|---|---|---|
| ២- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| ៣- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មួយចំនួន | សមាជិក |
| ៤- តំណាងធនាគារជាតិនៃកម្ពុជា | ១រូប | សមាជិក |
| ៥- តំណាងគណៈកម្មការមូលបត្រកម្ពុជា | ១រូប | សមាជិក |
| ៦- តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត | | សមាជិក |
| ៧- អគ្គលេខាធិការ **ក.ជ.គ.** | | សមាជិក |
| ៨- អ្នកជំនាញគណនេយ្យ និងសវនកម្ម | មួយចំនួន | សមាជិកពិគ្រោះយោបល់ |
| ៩- តំណាងសមាគមអាជីវកម្ម ឬអង្គការវិជ្ជាជីវៈ | មួយចំនួន | សមាជិកពិគ្រោះយោបល់ ។ |

សមាជិកពិគ្រោះយោបល់ អាចត្រូវបានតែងតាំងជាសមាសភាព **ក.ជ.គ.**តាមការចាំបាច់ ដើម្បីចូលរួមផ្តល់យោបល់ តែពុំមានសិទ្ធិចូលរួមបោះឆ្នោតធ្វើសេចក្តីសម្រេចឡើយ ។

សមាសភាពជាក់ស្តែងនៃ **ក.ជ.គ.**ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

តំណាងរបស់ក្រសួង និងស្ថាប័នដែលជាសមាសភាពនៃ **ក.ជ.គ.**ត្រូវមានសញ្ញាបត្រថ្នាក់ឧត្តមសិក្សាមានជំនាញ និងបទពិសោធពាក់ព័ន្ធនឹងគណនេយ្យសវនកម្ម ឬហិរញ្ញវត្ថុយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ។

ROYAUME DU CAMBODGE · LE SECRETARIAT DU PALAIS ROYAL

**មាត្រា ៧.-**

**ក.ជ.គ.**មានមុខងារ និងភារកិច្ចដូចតទៅ ៖

- រៀបចំធ្វើបច្ចុប្បន្នកម្ម និងអនុម័ត សេចក្តីព្រាង ៖

ក- ស្តង់ដាគណនេយ្យ

ខ- ស្តង់ដាសវនកម្ម

គ- វិធាន និងនីតិវិធីអនុវត្តស្តង់ដាគណនេយ្យ និងសវនកម្ម

- សម្រេចផ្តល់ ព្យួរ និងដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- រៀបចំ អនុម័ត និងអនុវត្តវិធាន និងនីតិវិធីសម្រាប់ការតាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម

- ពិនិត្យ និងដោះស្រាយបណ្តឹង ឬវិវាទពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម

- សម្រេចចាត់វិធានការវិន័យ ឬទណ្ឌកម្មរដ្ឋបាលចំពោះអំពើបំពានបទប្បញ្ញត្តិពាក់ព័ន្ធគណនេយ្យ និងសវនកម្ម

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅចំពោះមុខស្ថាប័នតុលាការ ចំពោះរឿងក្តីពាក់ព័ន្ធគណនេយ្យ និងសវនកម្ម

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិក្នុងការងារពាក់ព័ន្ធនឹងវិស័យគណនេយ្យ និងសវនកម្ម

- គ្រប់គ្រង និងអភិវឌ្ឍវិស័យគណនេយ្យ និងសវនកម្ម

- ពិនិត្យ តាមដាន និងវាយតម្លៃលើផែនការ ការអនុវត្តផែនការ និងសកម្មភាពរបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម

- ធ្វើជាតំណាងព្រះរាជាណាចក្រកម្ពុជានៅក្នុងអង្គការជាតិ និងអន្តរជាតិក្នុងវិស័យគណនេយ្យ និងសវនកម្ម ។

**មាត្រា ៨.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **ក.ជ.គ.**ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ **ក.ជ.គ.**ត្រូវមានថវិកាផ្ទាល់ខ្លួន ជាកញ្ចប់ដាច់ដោយឡែក ដែលជាផ្នែកមួយនៃថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

# ជំពូកទី ៣
# ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម

**មាត្រា ៩.-**

វិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង និងគាំពារដោយស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មតែមួយគត់និងឯករាជ្យក្នុងវិជ្ជាជីវៈ ។

**មាត្រា ១០.-**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៤
# ស្តង់ដាគណនេយ្យ

**មាត្រា ១១.-**

ស្តង់ដាគណនេយ្យ ត្រូវសម្រេចដាក់ឲ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ** ។

ស្តង់ដាគណនេយ្យមានអានុភាពអនុវត្តចំពោះស្ថាប័នសាធារណៈ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ។

# ជំពូកទី ៥
# ស្តង់ដាសវនកម្ម

**មាត្រា ១២.-**

ស្តង់ដាសវនកម្ម ត្រូវសម្រេចដាក់ឲ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ.** ។

ស្តង់ដាសវនកម្មមានអានុភាពអនុវត្តចំពោះសវនករទាំងអស់ ដែលប្រកបវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី ៦
## ក្រមសីលធម៌វិជ្ជាជីវៈ

**មាត្រា ១៣.-**

គណនេយ្យករមានក្រមសីលធម៌សម្រាប់វិជ្ជាជីវៈរបស់ខ្លួន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ.** ។

**មាត្រា ១៤.-**

សវនករមានក្រមសីលធម៌សម្រាប់វិជ្ជាជីវៈរបស់ខ្លួន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ.** ។

**មាត្រា ១៥.-**

សវនករមិនអាចផ្ដល់សេវាសវនកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលខ្លួនធ្លាប់ផ្ដល់សេវាគណនេយ្យឡើយ លើកលែងតែការផ្ដល់សេវាគណនេយ្យនោះបានបញ្ចប់ទៅក្នុងរយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

សវនករមិនត្រូវបន្តផ្ដល់សេវាកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញណាមួយលើសពីប្រាំឆ្នាំបន្តបន្ទាប់គ្នាឡើយ ។

សវនករមិនត្រូវផ្ដល់សេវាសវនកម្មជូនសហគ្រាសដែលខ្លួនទទួលផលប្រយោជន៍ ឬមានសិទ្ធិគ្រប់គ្រង ទោះដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី តាមរយៈសហព័ទ្ធ ញាតិលោហិត ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ ។

# ជំពូកទី ៧
## កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

**មាត្រា ១៦.-**

របាយការណ៍ហិរញ្ញវត្ថុរួមមានរបាយការណ៍នានាដែលត្រូវកំណត់ក្នុងស្តង់ដាគណនេយ្យ ។

**មាត្រា ១៧.-**

ក្រៅពីស្ថាប័នសាធារណៈ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យបានរួចរាល់ ក្នុងរយៈពេល ៣ (បី) ខែយ៉ាងយូរបំផុតគិតពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនីមួយៗ ។

ក្នុងករណីមិនអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមកាលកំណត់ក្នុងកថាខណ្ឌខាងលើ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវស្នើសុំពន្យារពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ជាលាយលក្ខណ៍អក្សរទៅ **ក.ជ.គ**. ឬទៅនិយ័តករពាក់ព័ន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដោយបញ្ជាក់ពីមូលហេតុសមស្រប និងច្បាស់លាស់ ។

**មាត្រា ១៨.-**

របាយការណ៍ហិរញ្ញវត្ថុអាចតម្រូវឲ្យធ្វើសវនកម្មតាមលក្ខខណ្ឌដែល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ **ក.ជ.គ**. ។

**មាត្រា ១៩.-**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាមូលដ្ឋានសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ២០.-**

សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ។

ស្ថាប័នសាធារណៈមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

ប្រតិបត្តិការគណនេយ្យនីមួយៗ ត្រូវសំអាងលើសក្ខីបត្រគណនេយ្យដែលមានសុពលភាព ។

**មាត្រា ២១.-**

ការិយបរិច្ឆេទគណនេយ្យនីមួយៗ ត្រូវកំណត់រយៈពេលចំនួន ១២ (ដប់ពីរ) ខែដោយគិតចាប់ពីថ្ងៃទី ១ ខែ មករា រហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដដែល ។

ចំពោះសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបង្កើតឡើងថ្មីការិយបរិច្ឆេទទី ១ ត្រូវគិតចាប់ពីកាលបរិច្ឆេទបង្កើតសហគ្រាស ឬអង្គភាពនោះជាផ្លូវការរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដដែល ។

ការិយបរិច្ឆេទគណនេយ្យ អាចត្រូវកំណត់ផ្សេងពីនេះ សម្រាប់សកម្មភាពដែលមានលក្ខណៈពិសេសដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ**.។

**មាត្រា ២២.-**

បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាភាសាខ្មែរ និងជាប្រាក់រៀល ។

ក្នុងករណីមានកិច្ចប្រតិបត្តិការអន្តរជាតិជាប្រចាំ បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានអនុញ្ញាតឲ្យធ្វើជាភាសាអង់គ្លេស និងជារូបិយបណ្ណបរទេស អមជាមួយបញ្ជីគណនេយ្យ និង

របាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរ និងប្រាក់រៀល តាមលក្ខខណ្ឌដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ.** ។

**មាត្រា ២៣.-**

គ្រប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចរក្សាទុករាល់ឯកសារគណនេយ្យរបស់ខ្លួនឲ្យបានគង់វង្សនៅក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការបង្កើតឯកសារ ។

## ជំពូកទី ៨
## របាយការណ៍សវនកម្ម

**មាត្រា ២៤.-**

របាយការណ៍សវនកម្ម រួមមានរបាយការណ៍នានាដែលត្រូវកំណត់ក្នុងស្តង់ដាសវនកម្ម ។

**មាត្រា ២៥.-**

របាយការណ៍សវនកម្មត្រូវរៀបចំឡើងជាភាសាខ្មែរ ដែលអាចអមដោយភាសាអង់គ្លេសមកជាមួយ ។

**មាត្រា ២៦.-**

ភស្តុតាងសវនកម្ម ត្រូវរក្សាទុកក្នុងរយៈពេល ១០ (ដប់) ឆ្នាំយ៉ាងតិចគិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍សវនកម្ម ។

## ជំពូកទី ៩
## គណនេយ្យករ និងសវនករ

**មាត្រា ២៧.-**

បុគ្គលគ្រប់រូបទោះជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី អាចជាគណនេយ្យករ និង/ឬសវនករបាន លុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ។

**មាត្រា ២៨.-**

ប្រភេទគណនេយ្យករ និងសវនករដែលជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ។

ការប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្មមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈ និងមុខងារនយោបាយក្នុងអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងមុខងារក្នុងអង្គការតុលាការ ។

ROYAUME DU CAMBODGE LE SECRÉTARIAT DU PALAIS ROYAL

## ជំពូកទី ១០
## អាជ្ញាបណ្ណ

**មាត្រា ២៩.-**

បុគ្គលគ្រប់រូបទោះជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី អាចប្រកបវិជ្ជាជីវៈជាគណនេយ្យករ ឬសវនករ បានលុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងទទួលបានអាជ្ញាបណ្ណពី **ក.ជ.គ.** ។

**មាត្រា ៣០.-**

អាជ្ញាបណ្ណចែកចេញជា ២ (ពីរ) ប្រភេទគឺអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ។

លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ.** ។

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

**មាត្រា ៣១.-**

គណនេយ្យករ ឬសវនករទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈ ត្រូវទទួលទណ្ឌកម្មណាមួយដូចខាងក្រោម ៖

- ការស្តីបន្ទោសដោយផ្ទាល់មាត់
- ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ការហាមមិនឲ្យប្រកបវិជ្ជាជីវៈជាបណ្តោះអាសន្ន
- ការហាមមិនឲ្យប្រកបវិជ្ជាជីវៈជាអចិន្ត្រៃយ៍ ។

**មាត្រា ៣២.-**

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៣.-**

ជនណាដែលប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្មដោយគ្មានអាជ្ញាបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ។

**មាត្រា ៣៤.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀលទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀលព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៣៥.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៨ ០០០ ០០០ (ប្រាំបីលាន) រៀលទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ចំពោះសវនករដែលក្លែងរបាយការណ៍សវនកម្ម ។

**មាត្រា ៣៦.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣៥ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀលទៅ ៥០ ០០០ ០០០(ហាសិបលាន) រៀលព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៣៧.-**

សវនករដែលមិនប្តឹងបរិហារពីបទល្មើសនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា ៥២៨ (បទមិនប្តឹងបរិហារបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយអ្នករាជការសាធារណៈ ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

## ជំពូកទី ១២
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលត្រូវបានដាក់ឲ្យអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ត្រូវបន្តអានុភាពគតិយុត្ត រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ។

# ជំពូកទី ១៣
# អវសានប្បញ្ញត្តិ

**មាត្រា ៣៩.-**

ច្បាប់ស្តីពីគណនេយ្យសហគ្រាសសវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម. ០៤១៦.០០៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

លេខ: ៣៤៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

# សទ្ទានុក្រម
# ជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម

បច្ចេកស័ព្ទជាសារវ័ន្ត ដែលត្រូវបានប្រើក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្មមាននិយមន័យដូចតទៅ ៖

១- **ក្រមសីលធម៌វិជ្ជាជីវៈ** សំដៅដល់ គោលការណ៍ តម្លៃ ស្តង់ដា ឬវិធាននានាដែលកំណត់អំពីឥរិយាបទរបស់គណនេយ្យករនិងសវនករក្នុងវិជ្ជាជីវៈរបស់ខ្លួន ។

២- **គណនេយ្យ** សំដៅដល់ការកត់ត្រា ការចាត់ថ្នាក់ ការវាស់វែង ការផ្តុំបញ្ចូលគ្នា និងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ ។

៣- **គណនេយ្យករ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ។

៤- **បញ្ជីគណនេយ្យ** សំដៅដល់សៀវភៅ/បញ្ជីសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យដែលរួមមានសក្ខីប័ត្រគណនេយ្យទិន្នានុលេខន៍ សៀវភៅធំជាដើម ។

៥- **ភស្តុតាងសវនកម្ម** សំដៅដល់ព័ត៌មានដែលបានប្រើដោយសវនករសម្រាប់ធ្វើការសន្និដ្ឋាន និងដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិរបស់សវនករ ។ ភស្តុតាងសវនកម្ម រួមមានព័ត៌មានដែលមាននៅក្នុងបញ្ជីគណនេយ្យសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានផ្សេងៗទៀត ។

៦- **របាយការណ៍សវនកម្ម** សំដៅដល់យោបល់ ឬការបដិសេធផ្លូវការ ដែលបានចេញដោយសវនករជាលទ្ធផលនៃការធ្វើសវនកម្ម ឬការវាយតម្លៃដែលបានធ្វើលើនីតិបុគ្គល ឬផ្នែកណាមួយនៃនីតិបុគ្គលនោះ (ដែលហៅថា "នីតិបុគ្គលរងសវនកម្ម") ។

៧- **របាយការណ៍ហិរញ្ញវត្ថុ** សំដៅដល់ការលាតត្រដាងជារចនាសម្ព័ន្ធនៃព័ត៌មានហិរញ្ញវត្ថុដោយរួមបញ្ចូលទាំងកំណត់សម្គាល់ពាក់ព័ន្ធផង ក្នុងគោលបំណងផ្សព្វផ្សាយអំពីធនធានសេដ្ឋកិច្ច ឬកាតព្វកិច្ចរបស់អង្គភាព នៅត្រឹមចំណុចមួយនៃពេលវេលា ឬបម្រែបម្រួលនានានៃធនធានសេដ្ឋកិច្ច និងកាតព្វកិច្ចសម្រាប់ការិយបរិច្ឆេទមួយ ដោយអនុលោមតាមក្របខណ្ឌនៃការរាយការណ៍ហិរញ្ញវត្ថុ ។ កំណត់សម្គាល់ពាក់ព័ន្ធ រួមមានសេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងៗទៀត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨- **សវនកម្ម** សំដៅដល់ការត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យនិងជាប្រព័ន្ធ លើទិន្នន័យរបាយការណ៍កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់សហគ្រាសសម្រាប់គោលបំណងជាក់លាក់ណាមួយ ។

៩- **សវនករ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលអនុវត្តការងារសវនកម្ម និងជាសមាជិកសកម្មរបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ។

១០- **សហគ្រាស** សំដៅដល់អង្គភាព ឬគ្រឹះស្ថានដែលមានគោលដៅស្វែងរកប្រាក់ចំណេញ ដែលរួមមានសហគ្រាសសាធារណៈ និងសហគ្រាសឯកជន រួមទាំងធនាគារគ្រឹះស្ថានហិរញ្ញវត្ថុ និងសហគ្រាសធុនតូច និងមធ្យម ព្រមទាំងមីក្រូសហគ្រាសផងដែរ ។

១១- **ស្តង់ដាគណនេយ្យ** សំដៅដល់សំណុំនៃសេចក្តីណែនាំសម្រាប់អ្នករៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រើដើម្បីរៀបចំ និងលាតត្រដាងពីចំណូល ចំណាយ ទ្រព្យសកម្មបំណុល និងមូលធនរបស់អង្គភាព ព្រមទាំងព័ត៌មានចាំបាច់ផ្សេងទៀត ។

១២- **ស្តង់ដាសវនកម្ម** សំដៅដល់សំណុំនៃសេចក្តីណែនាំ ឬបទដ្ឋាននានាដែលបានប្រើដោយសវនករនៅក្នុងការអនុវត្តការងារសវនកម្ម ។

១៣- **ស្តង់ដាអន្តរជាតិ** សំដៅដល់ស្តង់ដាគណនេយ្យ ឬស្តង់ដាសវនកម្ម ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មចំពោះស្តង់ដានីមួយៗនោះផងដែរដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ និងសហព័ន្ធគណនេយ្យករអន្តរជាតិ ។

១៤- **ស្ថាប័នសាធារណៈ** សំដៅដល់ស្ថាប័ននៃអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងអង្គការតុលាការនៃព្រះរាជាណាចក្រកម្ពុជារាប់បញ្ចូលទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលផង ។

១៥- **អង្គភាពមិនស្វែងរកប្រាក់ចំណេញ** សំដៅដល់អង្គភាពដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងមិនស្វែងរកផលចំណេញដោយអនុលោមតាមច្បាប់ជាធរមាន ។

១៦- **អ្នកជំនាញគណនេយ្យនិងសវនកម្ម** សំដៅដល់សមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ដែលមិនអនុវត្តវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម ក្នុងពេលដែលសាមីខ្លួនកំពុងតែជាសមាជិករបស់ **ក.ជ.គ.** ។

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៣៣២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៤ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈ ៖

១-ឯកឧត្តម **គីម ណុខ** ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន។

២-ឯកឧត្តម **នី ផល្លី** ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន។

៣-ឯកឧត្តម **លឹម អ៊ីវ** ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន។

៤-ឯកឧត្តម **កែវ កុសល** ជាទីប្រឹក្សាបច្ចេកទេសនៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា មានឋានៈស្មើអគ្គនាយក។

៥-ឯកឧត្តម **ខិន សុភាព** ជាទីប្រឹក្សាបច្ចេកទេសនៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា មានឋានៈស្មើអគ្គនាយក។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ស្ល.១៦០៤.៣៣៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦*

លេខៈ ៣៧៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៤១៦/៣៧៣

# ព្រះរាជក្រឹត្យ
## ស្តីពី
## លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា**
**សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦

## ទ្រាស់បន្ទាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះមានគោលបំណងដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានសមត្ថភាព ផលិតភាព ប្រសិទ្ធភាព និងប្រសិទ្ធផល សំដៅឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា២ .-**

ព្រះរាជក្រឹត្យនេះមានគោលដៅកំណត់៖

- ការរៀបចំនិងគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំនិងគ្រប់គ្រងបុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣ .-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលរួមមាន៖

- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានជ្រើសរើសនិងតែងតាំងដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នដែលត្រូវបានផ្ទេរតាមដំណើរការនៃការផ្ទេរមុខងារនិងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័នដែលត្រូវបានតែងតាំងឬចាត់តាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិ ឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- បុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិល រួមមាន មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

មន្ត្រីរាជការនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលឬមន្ត្រីដទៃទៀតដែលអនុវត្តភារកិច្ចពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ មិនស្ថិតក្រោមវិសាលភាពនៃព្រះរាជក្រឹត្យនេះទេ។

## ជំពូកទី២
## គោលការណ៍រួម

**មាត្រា៤ .-**

ការរៀបចំនិងការគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ ._**

ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធានានូវគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព អព្យាក្រឹត្យភាព និងសមធម៌។

**មាត្រា៦ ._**

ការផ្ទេរនិងការផ្លាស់ប្តូរទៅវិញទៅមករវាងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ ត្រូវធានាដល់ការការពារផលប្រយោជន៍នានារបស់បុគ្គលិកនិងប្រសិទ្ធភាពការងារ។

**មាត្រា៧ ._**

ការជ្រើសរើស ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការតែងតាំងមុខតំណែង និងការផ្តល់ការលើកទឹកចិត្តផ្សេងៗ ត្រូវផ្តល់អាទិភាពដល់ស្ត្រី ជនជាតិដើមភាគតិច និងជនពិការ ដោយផ្អែកលើសមត្ថភាពការងារនិងគុណធម៌។

## ជំពូកទី៣
## អង្គ ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់

**មាត្រា៨ ._**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវស្ថិតនៅក្នុងអង្គ ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដែលត្រូវអនុវត្តទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ។

**មាត្រា៩ ._**

មុខតំណែងក្នុងអង្គដើម្បីបម្រើការងារនៅតាមរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនិងមុខតំណែងដើម្បីគាំទ្រប្រតិបត្តិការការងារ បេសកកម្ម និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការពិគ្រោះយោបល់ពីក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៤
## ការរៀបចំផែនការនិងការជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១០ ._**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗទទួលខុសត្រូវរៀបចំផែនការបុគ្គលិកគ្រប់ប្រភេទក្របខណ្ឌនៅពេលមានតម្រូវការធនធានមនុស្សដើម្បីបំពេញភារកិច្ចនិងករណីយកិច្ចឆ្លើយតបទៅនឹងតម្រូវការការងារដែលក្រុមប្រឹក្សាត្រូវអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ចំពោះការរៀបចំផែនការបុគ្គលិករបស់រដ្ឋបាលរាជធានី ត្រូវដាក់បញ្ចូលនូវផែនការបុគ្គលិករបស់រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ចំពោះការរៀបចំផែនការបុគ្គលិករបស់រដ្ឋបាលក្រុង ត្រូវដាក់បញ្ចូលនូវផែនការបុគ្គលិករបស់រដ្ឋបាលសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំនីមួយៗឱ្យបានរួចរាល់ក្នុងត្រីមាសទី១នៃឆ្នាំ ដើម្បីដាក់បញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំបន្ទាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមបែបបទនិងនីតិវិធីជាធរមាន ដោយមានការគាំទ្រពីមន្ទីរមុខងារសាធារណៈនិងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។/.

**មាត្រា១១ ._**

ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ ត្រូវផ្អែកទៅលើគោលនយោបាយនិងក្របខណ្ឌម៉ាក្រូហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗរបស់រាជរដ្ឋាភិបាល ចំនួនមុខតំណែងដែលនៅទំនេរ តម្រូវការបុគ្គលិកផ្អែកលើទំហំការងារ ការកែសម្រួលរចនាសម្ព័ន្ធ និងការផ្ទេរមុខងារ។

គោលការណ៍ បែបបទ និងនីតិវិធីនៃការរៀបចំផែនការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា១២ ._**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការរៀបចំជ្រើសរើសបេក្ខជនសម្រាប់មុខតំណែងវិជ្ជាជីវៈនីមួយៗផ្អែកតាមផែនការបុគ្គលិកប្រចាំឆ្នាំរបស់ខ្លួន លើកលែងតែការជ្រើសរើសបេក្ខជនសម្រាប់មុខតំណែងវិជ្ជាជីវៈអប់រំនិងសុខាភិបាលដែលត្រូវជ្រើសរើសដោយថ្នាក់ជាតិ។

បេក្ខជនដែលត្រូវបានជ្រើសរើសសម្រាប់មុខតំណែងវិជ្ជាជីវៈនីមួយៗក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ លុះត្រាតែបេក្ខជនទាំងនោះបានបំពេញតាមគ្រប់លក្ខខណ្ឌតម្រូវដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា អង្គ ប្រភេទក្របខណ្ឌ មុខតំណែងវិជ្ជាជីវៈនីមួយៗរបស់មន្ត្រីរាជការស៊ីវិល ព្រមទាំងនិយាមជាតិជាធរមាន។

រដ្ឋបាលថ្នាក់ក្រោមជាតិអាចកំណត់លក្ខខណ្ឌបន្ថែមផ្អែកលើភាពចាំបាច់នៃមុខតំណែងវិជ្ជាជីវៈនីមួយៗ ដើម្បីគាំទ្រដំណើរការការងារនិងបេសកកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៣ ._**

ការជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្អែកលើគោលការណ៍តម្លាភាព យុត្តិធម៌ សមធម៌ និងគុណសម្បត្តិស័ក្តិសម។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវរៀបចំឱ្យមានគណៈកម្មការរៀបចំការប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយឡែករដ្ឋបាលរាជធានី ត្រូវរៀបចំឱ្យមានគណៈកម្មការរៀបចំការប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលសម្រាប់រាជធានី ខណ្ឌ និងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយរដ្ឋបាលក្រុង ត្រូវរៀបចំឱ្យមានគណៈកម្មការរៀបចំការប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលសម្រាប់ក្រុងនិងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណៈកម្មការនេះត្រូវមានសមាសភាពដូចខាងក្រោម៖

**ក- សម្រាប់រដ្ឋបាលរាជធានី**

- តំណាងគណៈអភិបាល ប្រធាន
- នាយករដ្ឋបាល សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបុគ្គលិក សមាជិក
- ប្រធានអង្គភាពដែលមានតម្រូវការបុគ្គលិក សមាជិក
- អភិបាលខណ្ឌនិង/ឬចៅសង្កាត់ដែលមានតម្រូវការបុគ្គលិក សមាជិក
- តំណាងមន្ទីរមុខងារសាធារណៈ សមាជិក

**ខ- សម្រាប់រដ្ឋបាលខេត្ត ស្រុក**

- តំណាងគណៈអភិបាល ប្រធាន

- នាយករដ្ឋបាល — សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបុគ្គលិក — សមាជិក
- ប្រធានអង្គភាពដែលមានតម្រូវការបុគ្គលិក — សមាជិក
- តំណាងមន្ទីរមុខងារសាធារណៈ — សមាជិក

គ- សម្រាប់រដ្ឋបាលក្រុង

- តំណាងគណៈអភិបាល — ប្រធាន
- នាយករដ្ឋបាល — សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបុគ្គលិក — សមាជិក
- ប្រធានអង្គភាពដែលមានតម្រូវការបុគ្គលិក — សមាជិក
- ចៅសង្កាត់ដែលមានតម្រូវការបុគ្គលិក — សមាជិក
- តំណាងមន្ទីរមុខងារសាធារណៈ — សមាជិក

ឃ- សម្រាប់រដ្ឋបាលឃុំ សង្កាត់(ក្រៅខណ្ឌនិងក្រុង)

- មេឃុំឬចៅសង្កាត់ — ប្រធាន
- ជំទប់ទី១ឬចៅសង្កាត់រងទី១ — អនុប្រធាន
- ស្មៀនឃុំឬសង្កាត់ — សមាជិក
- តំណាងមន្ទីរមុខងារសាធារណៈ — សមាជិក

ក្រុមប្រឹក្សាត្រូវធានាឱ្យមានបេក្ខភាពជាស្ត្រីយ៉ាងតិច១(មួយ)រូបនៅក្នុងសមាសភាពនៃគណៈកម្មការនេះ។ ក្នុងករណីដែលមិនមានបេក្ខភាពជាស្ត្រីក្នុងចំណោមសមាសភាពដូចបានកំណត់ខាងលើ ក្រុមប្រឹក្សាអាចបន្ថែមសមាសភាពជាស្ត្រី១(មួយ)រូបជាសមាជិកគណៈកម្មការនេះ។

គណៈកម្មការនេះមានសិទ្ធិក្នុងការបង្កើតអនុគណៈកម្មការនិង/ឬក្រុមការងារតាមការចាំបាច់ ដើម្បីរៀបចំការប្រឡងនេះ។

**មាត្រា១៤ .-**

ការប្រឡងជ្រើសរើសត្រូវផ្តល់អាទិភាពជូនបេក្ខជនជានារីភេទ ជនជាតិដើមភាគតិច ជនពិការ និងបេក្ខជនមានលំនៅឋានស្ថិតនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលមានតម្រូវការបុគ្គលិក។

**មាត្រា១៥ .-**

កាលបរិច្ឆេទនៃការប្រឡងប្រជែងចូលក្នុងក្របខណ្ឌបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំនិងផ្សព្វផ្សាយរយៈពេល៣(បី)ខែមុនការប្រឡងចាប់ផ្តើមដំណើរការ។ ក្នុងករណីដែលមានការប្រញាប់ រយៈពេលនេះអាចកាត់បន្ថយមកត្រឹម៣០(សាមសិប)ថ្ងៃ។

**មាត្រា១៦ .-**

លទ្ធផលនៃការប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៧ .-**

ដំណើរការនៃការរៀបចំប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៥
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ចប់កម្មសិក្សា
## របស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១៨ .-**

ការធ្វើកម្មសិក្សាត្រូវអនុវត្តចំពោះបេក្ខជនដែលមានឈ្មោះប្រឡងជាប់ស្ថាពរក្នុងដីកាប្រកាសលទ្ធផលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- រយៈពេលកម្មសិក្សា១២(ដប់ពីរ)ខែ ចំពោះកម្មសិក្សាការីដែលត្រូវបានជ្រើសចេញពីសិស្ស និស្សិត
- រយៈពេលកម្មសិក្សា៦(ប្រាំមួយ)ខែចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតាំងស៊ប់ក្នុងក្របខណ្ឌណាមួយរួចហើយ ហើយបានប្រឡងជាប់ចូលក្របខណ្ឌណាមួយនៃអង្គថ្មីមួយទៀត ដោយរក្សាអតីតភាពដែលមានពីមុនមក លើកលែងតែមានការកំណត់មិនឱ្យធ្វើកម្មសិក្សាដោយអង្គណាមួយ
- ការធ្វើកម្មសិក្សា ត្រូវបានលើកលែងចំពោះមន្ត្រីរាជការក្របខណ្ឌទាំងឡាយដែលបានប្រឡងជាប់ទៅកាន់ប្រភេទក្របខណ្ឌខ្ពស់ជាងមុនក្នុងអង្គតែមួយដែលបានតាំងស៊ប់រួចហើយ លើកលែងតែមានការកំណត់ឱ្យធ្វើកម្មសិក្សាដោយអង្គណាមួយ
- កម្មសិក្សាមិនត្រូវយកជាការបានឡើយ ប្រសិនបើសាមីជនអាក់ខានមកធ្វើកម្មសិក្សាដែលមានរយៈពេលសរុបលើសពី៣០ថ្ងៃ។ ក្នុងករណីនេះ សាមីជនត្រូវបន្តកម្មសិក្សានៅលើកទី២ទៀត
- កម្មសិក្សាការីណាដែលមិនបានបង្ហាញឱ្យឃើញថា ខ្លួនមានកាយសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ឬក៏ពិនិត្យឃើញថាការធ្វើការងារមានការខ្ជីខ្ជា ឬក៏គ្មានកម្លាំងពលំនឹងកាន់មុខតំណែងបានតាមលក្ខខណ្ឌដែលបានកំណត់ក្នុងសេចក្តីណែនាំជាធរមាន អាចត្រូវបានបញ្ឈប់មិនឱ្យធ្វើការងារនេះនៅពេលណាក៏បានក្នុងរយៈពេលកម្មសិក្សា។

**មាត្រា១៩ .-**

ការតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គណាមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុញ្ញាតជូនកម្មសិក្សាការីទាំងឡាយណាដែលបានបញ្ចប់កម្មសិក្សាដោយជោគជ័យ។

ការតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គណាមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃដែលមានសមាសភាពដូចជា ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់១(មួយ)រូប អនុប្រធានអង្គភាពសាមី១(មួយ)រូប និងមន្ត្រីរាជការ១(មួយ)រូបដែលមានឋានន្តរស័ក្តិខ្ពស់ជាងគេក្នុងអង្គភាពដែលសាមីខ្លួនធ្វើការជាមួយ។ ក្នុងករណីពុំមានមន្ត្រីរាជការសមស្របតាមការកំណត់ខាងលើនេះទេ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ជាអ្នកវាយតម្លៃ។ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ត្រូវលើកសំណើតាមឋានានុក្រមដាក់ជូនអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យសម្រេច។

ចំពោះមន្ត្រីរាជការស៊ីវិលដែលបានប្រឡងជាប់ទៅកាន់ប្រភេទក្របខណ្ឌខ្ពស់ជាងមុនក្នុងអង្គតែមួយនិងមន្ត្រីរាជការស៊ីវិលដែលប្រឡងប្តូរប្រភេទក្របខណ្ឌរវាងអង្គផ្សេងគ្នា ត្រូវអនុញ្ញាតឱ្យតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គដែលខ្លួនបានប្រឡងជាប់បន្ទាប់ពីការចេញដីកាប្រកាសលទ្ធផល។

**មាត្រា២០ .-**

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរក្រោយផុតកំណត់រយៈពេលកម្មសិក្សា ដោយផ្អែកលើការវាយតម្លៃរបស់គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃកម្មសិក្សា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចអំពី៖

- ការតាំងស៊ប់កម្មសិក្សាការីក្នុងក្របខណ្ឌ ឬ

- ការឱ្យកម្មសិក្សាការីធ្វើកម្មសិក្សាជាលើកទី២ ឬ
- ការបញ្ឈប់មិនឱ្យកម្មសិក្សាការីធ្វើការ។

ការតាំងស៊ប់ចាប់ផ្តើមមានប្រសិទ្ធភាពចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សា។ រយៈពេលកម្មសិក្សាត្រូវគិតបញ្ចូលក្នុងអតីតភាពការងារសម្រាប់ពេលចូលនិវត្តន៍។

**មាត្រា២១ .-**

ការតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គនីមួយៗ ត្រូវអនុវត្តតាមការកំណត់ដូចខាងក្រោម៖

- ត្រូវចាត់បញ្ចូលទៅក្នុងថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលបេក្ខជនបានប្រឡងជាប់ ចំពោះបេក្ខជនដែលបានជ្រើសរើសចេញពីសិស្ស និស្សិត ឬត្រូវបានបន្ថែម១(មួយ)ថ្នាក់ឬច្រើនថ្នាក់ទៅតាមការកំណត់នៃក្របខណ្ឌនីមួយៗនៃអង្គឬតាមការកំណត់របស់រាជរដ្ឋាភិបាល
- ត្រូវចាត់បញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ចំពោះបេក្ខជនដែលបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិល។

**មាត្រា២២ .-**

ការសម្រេចឱ្យធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខណ្ឌ ឬការបញ្ឈប់មិនឱ្យកម្មសិក្សាការីធ្វើការ ត្រូវធ្វើឡើងដោយដឹការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីជាធរមាន។

**មាត្រា២៣ .-**

បែបបទនិងនីតិវិធីនៃការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ឈប់កម្មសិក្សា ត្រូវរៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៦
## ការតែងតាំងនិងការបញ្ចប់មុខតំណែង

**មាត្រា២៤ .-**

ក្រោយពេលត្រូវបានតាំងស៊ប់នៅក្នុងក្របខណ្ឌរួចហើយ មន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបានការតែងតាំងក្នុងមុខតំណែងវិជ្ជាជីវៈស្របតាមសេចក្តីត្រូវការនៃការជ្រើសរើសបានកំណត់។

ការតែងតាំងក្នុងមុខតំណែងវិជ្ជាជីវៈ ត្រូវផ្អែកលើគុណសម្បត្តិស័ក្តិសមនៃមុខតំណែងវិជ្ជាជីវៈនីមួយៗដែលត្រូវកំណត់ដោយអនុក្រឹត្យនិងលិខិតបទដ្ឋានជាធរមាន។

**មាត្រា២៥ .-**

ការតែងតាំងក្នុងមុខតំណែងគ្រប់គ្រងត្រូវផ្អែកលើឧបនិស្ស័យនិងគុណសម្បត្តិស័ក្តិសមរបស់បេក្ខជនសម្រាប់មុខតំណែងអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៦ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចត្រូវបញ្ចប់មុខតំណែងវិជ្ជាជីវៈឬមុខតំណែងគ្រប់គ្រងក្នុងករណីដូចខាងក្រោម៖

- មរណភាព
- ការចូលនិវត្តន៍ឬការដាក់ឱ្យចូលនិវត្តន៍មុនកំណត់
- ការបាត់បង់សម្បទាវិជ្ជាជីវៈ

- ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម
- ការបញ្ឈប់ពីការងារដោយបង្ខំឬការបណ្តេញចេញពីមុខតំណែងមន្ត្រីរាជការ
- ការលាឈប់ពីមុខតំណែង
- ការផ្ទេរឬផ្លាស់ប្តូរកន្លែងធ្វើការ
- ការផ្តន្ទាទោសជាបទឧក្រិដ្ឋឬជាបទមជ្ឈិមដោយឥតព្យួរទោស
- ការលុបនិងការកែសម្រួលរចនាសម្ព័ន្ធនិងមុខតំណែង។

**មាត្រា២៧ .-**

ការតែងតាំងនិងការបញ្ចប់មុខតំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលខេត្ត ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលសាមីនីមួយៗតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការតែងតាំងនិងការបញ្ចប់មុខតំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានី ខណ្ឌ និងសង្កាត់ក្នុងខណ្ឌ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលរាជធានីតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការតែងតាំងនិងការបញ្ចប់មុខតំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលក្រុងនិងសង្កាត់ក្នុងក្រុង ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលក្រុងតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការតែងតាំងនិងការបញ្ចប់មុខតំណែងខាងលើនេះមិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលច្បាប់តម្រូវឱ្យមានការតែងតាំងឬបញ្ចប់មុខតំណែងដោយរាជរដ្ឋាភិបាលឬដោយក្រសួង ស្ថាប័នថ្នាក់ជាតិឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចលើកសំណើតែងតាំងនិងបញ្ចប់មុខតំណែងមន្ត្រីរាជការស៊ីវិលទាំងនេះមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចនិង/ឬស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា២៨ .-**

បែបបទនិងនីតិវិធីនៃការតែងតាំងនិងការបញ្ចប់មុខតំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួងស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៧

## ការដំឡើងថ្នាក់និងឋានន្តរស័ក្តិបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា២៩ .-**

ការដំឡើងថ្នាក់ និង/ឬ ឋានន្តរស័ក្តិបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តផ្អែកលើការវាយតម្លៃគុណផលការងាររបស់បេក្ខជន។

ការវាយតម្លៃគុណផលការងារនេះ ត្រូវធ្វើឡើងដោយគណៈកម្មការវាយតម្លៃគុណផលការងារដែលមានសមាសភាពដូចគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃការតាំងស៊ប់ដែលមានចែងក្នុងមាត្រា១៩នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៣០**

ការដំឡើងថ្នាក់របស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដូចខាងក្រោម៖

- រយៈពេលអប្បបរមានៃការឡើងថ្នាក់ត្រូវកំណត់រយៈពេល២(ពីរ)ឆ្នាំ។ ការដំឡើងថ្នាក់អាចធ្វើបានម្តងតែមួយថ្នាក់។ អតីតភាពការងារមន្ត្រីរាជការដែលធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល

តំបន់ប៉ះពាល់សុខភាពឬគ្រោះថ្នាក់ត្រូវគិតបន្ថែមពាក់កណ្តាលនៃអតីតភាពនេះទៀតក្នុងការចុះឈ្មោះលើតារាងរាយនាមសម្រាប់ស្នើសុំដំឡើងថ្នាក់។

- អតីតភាពបម្រើការងារគិតចាប់ពីថ្ងៃតាំងស៊ប់ឬថ្ងៃឡើងថ្នាក់ចុងក្រោយដល់ថ្ងៃទី១៣ ខែមេសានៃឆ្នាំនីមួយៗ។

**មាត្រា៣១ ..**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដំឡើងថ្នាក់ជាស្វ័យប្រវត្តិ ក្នុងករណីដូចខាងក្រោម៖

- បានទទួលការបណ្តុះបណ្តាលដោយជោគជ័យវគ្គសុក្រឹត្យការឬវិក្រឹត្យការនៅសាលាភូមិន្ទរដ្ឋបាល
- បានទទួលការបណ្តុះបណ្តាលជំនាញសមស្របតាមការតម្រូវនៃអង្គរបស់ខ្លួន ដែលមានរយៈពេលយ៉ាងតិច១(មួយ)ឆ្នាំ ដោយមានសញ្ញាបត្រឬវិញ្ញាបនបត្របញ្ជាក់ទទួលស្គាល់
- មានអតីតភាពការងារយ៉ាងតិច២(ពីរ)ឆ្នាំសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានអនុញ្ញាតឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម ដើម្បីទៅបំពេញមុខងារនៅតាមស្ថាប័នសាធារណៈផ្សេងទៀត។

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបានការដំឡើងថ្នាក់តាមការបណ្តុះបណ្តាលមានសិទ្ធិស្នើសុំការដំឡើងថ្នាក់ប្រចាំឆ្នាំផ្អែកលើអតីតភាពការងារដូចមានចែងក្នុងមាត្រា៣០ខាងលើ។

**មាត្រា៣២ ..**

ក្នុងករណីបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិណាម្នាក់ បានបំពេញការងារមានស្នាដៃល្អពិសេស អាចត្រូវបានដំឡើងថ្នាក់ដោយពុំគិតពីលក្ខខណ្ឌអតីតភាពឡើយ។

**មាត្រា៣៣ ..**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតនៅថ្នាក់ខ្ពស់បំផុតឬថ្នាក់លេខ១នៃឋានន្តរស័ក្តិទី២និងទី៣ក្នុងក្របខណ្ឌប្រភេទ"ក"និង"ខ"នៃអង្គនីមួយៗ ត្រូវបានដំឡើងទៅថ្នាក់ទាបបំផុតនៃឋានន្តរស័ក្តិខ្ពស់បន្ទាប់នៃប្រភេទក្របខណ្ឌរបស់មន្ត្រីរាជការស៊ីវិលនោះ លុះត្រាតែបុគ្គលិកជាមន្ត្រីរាជការនោះ បានបំពេញលក្ខខណ្ឌសម្រាប់ការឡើងថ្នាក់ដូចបានកំណត់ក្នុងមាត្រា៣០ មាត្រា៣១ និងមាត្រា៣២នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៣៤ ..**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈក្នុងករណីទទួលមរណភាពដោយសារបំពេញបេសកកម្មឬគ្រោះថ្នាក់ការងារ។

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិជាកិត្តិយសក្នុងករណីបាត់បង់សម្បទាវិជ្ជាជីវៈដោយមូលហេតុបំពេញការងារឬក្នុងករណីចូលនិវត្តន៍។

**មាត្រា៣៥ ..**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រភេទក្របខណ្ឌណាមួយអាចត្រូវដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិដល់ត្រឹមកម្រិតខ្ពស់បំផុតក្នុងប្រភេទក្របខណ្ឌនោះតែប៉ុណ្ណោះ ដោយពុំអាចធ្វើការដំឡើងទៅក្នុងថ្នាក់និង/ឬឋានន្តរស័ក្តិនៃប្រភេទក្របខណ្ឌផ្សេងទៀតបានឡើយ។

**មាត្រា៣៦ ..**

ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលខេត្ត ស្រុក និងឃុំ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សារបស់រដ្ឋបាលសាមីនីមួយៗតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានី ខណ្ឌ និងសង្កាត់ក្នុងខណ្ឌ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលរាជធានីតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលក្រុងនិងសង្កាត់ក្នុងក្រុង ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលក្រុងតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិខាងលើនេះមិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិពិនិត្យ វាយតម្លៃ និងលើកសំណើសម្រាប់ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិលទាំងនោះមកក្រសួងមហាផ្ទៃដើម្បីពិនិត្យសម្រេចតាមនីតិវិធីជាធរមាន។

**មាត្រា៣៧ .-**

បែបបទនិងនីតិវិធីនៃការដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួងស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៨
## ការផ្ទេរនិងការផ្លាស់ប្តូរកន្លែងធ្វើការ

**មាត្រា៣៨ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ អាចត្រូវបានអនុញ្ញាតឱ្យផ្ទេរទៅវិញទៅមករវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិនិងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៀត។

ការផ្ទេរនេះអាចធ្វើឡើងបានក្នុងអង្គតែមួយនៃមន្ត្រីរាជការនោះនិងត្រូវផ្អែកលើមុខតំណែងទំនេរនៅក្នុងអង្គភាពដែលទទួលបុគ្គលិកនោះ ព្រមទាំងគុណសម្បត្តិស័ក្តិសមរបស់បុគ្គលិកចំពោះមុខតំណែង។

ការផ្ទេរបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវធ្វើឡើងតាមគោលការណ៍ដូចខាងក្រោម៖

**ក- ការផ្ទេរពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយផ្សេងទៀត**

- ការស្នើសុំរបស់សាមីខ្លួន
- ការយល់ព្រមពីអភិបាល មេឃុំ ចៅសង្កាត់នៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងសងខាង
- ការផ្ទេរនេះត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងសងខាង
- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបញ្ជូនដីកាសម្រេចផ្ទេរបុគ្គលិកទៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្តដែលសាមីខ្លួននោះផ្ទេរទៅ។ ក្នុងករណីពិនិត្យឃើញដីកានិងសេចក្តីសម្រេចធ្វើឡើងមិនស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការឡើយ។

**ខ- ការផ្ទេររវាងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ**

- ការស្នើសុំរបស់សាមីខ្លួន
- ការយល់ព្រមពីអភិបាល មេឃុំ ចៅសង្កាត់នៃរដ្ឋបាលថ្នាក់ក្រោមជាតិសាមី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

- ការយល់ព្រមពីក្រសួង ស្ថាប័នសាមី
- ការផ្ទេរនេះធ្វើឡើងដោយដីកាបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងប្រកាសរបស់ក្រសួង ស្ថាប័នសាមី។
- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបញ្ជូនដីកាឬប្រកាសសម្រេចផ្ទេរបុគ្គលិកទៅក្រសួងមុខងារសាធារណៈ។

ក្នុងករណីពិនិត្យឃើញដីកានិងប្រកាសធ្វើឡើងមិនស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ ក្រសួងមុខងារសាធារណៈមិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការឡើយ។

**មាត្រា៣៩ .-**

ការផ្ទេរបុគ្គលិកជាមន្ត្រីរាជការស៊ីវិលតាមមាត្រា៣៨ខាងលើនេះ មិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**មាត្រា៤០ .-**

ការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់មន្ត្រីរាជការស៊ីវិលពីអង្គភាពមួយទៅអង្គភាពមួយក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី។

**មាត្រា៤១ .-**

ការផ្ទេរនិងការផ្លាស់ប្តូរកន្លែងធ្វើការដូចមានចែងក្នុងមាត្រា៣៨និងមាត្រា៤០ខាងលើត្រូវរក្សាអត្ថប្រយោជន៍ដែលសាមីជនធ្លាប់បានទទួលកន្លងមកមានដូចជា ក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ និងអតីតភាពការងារជាដើម។

**មាត្រា៤២ .-**

បែបបទនិងនីតិវិធីនៃការផ្ទេរនិងការផ្លាស់ប្តូរកន្លែងធ្វើការរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួងស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៩
## ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬការដាក់ឱ្យនៅក្រៅតំណែង

**មាត្រា៤៣ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចត្រូវបានដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬដាក់ឱ្យនៅក្រៅតំណែង ដើម្បីទៅបំពេញការងារជាសមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល និងនៅក្នុងស្ថាប័នសាធារណៈផ្សេងទៀត។

**មាត្រា៤៤ .-**

ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬការដាក់ឱ្យនៅក្រៅតំណែងរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវសម្រេចដោយក្រសួងមហាផ្ទៃឬរាជរដ្ឋាភិបាលផ្អែកលើករណីនីមួយៗ។

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬដាក់ឱ្យនៅក្រៅតំណែង ត្រូវរក្សាទុកអតីតភាពសម្រាប់ការឡើងថ្នាក់ ការឡើងឋានន្តរស័ក្តិ និងការចូលនិវត្តន៍នៅអង្គភាពដើម។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី១០
## ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

**មាត្រា៤៥ .-**

ភាពទំនេរគ្មានបៀវត្ស គឺជាស្ថានភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលបាត់សិទ្ធិទទួលប្រាក់បៀវត្ស ការឡើងថ្នាក់ ការឡើងឋានន្តរស័ក្តិ និងអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍។

ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស អាចធ្វើឡើងតាមការស្នើសុំរបស់មន្ត្រីសាមីជនឬដោយបញ្ញត្តិអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៤៦ .-**

ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សតាមពាក្យស្នើសុំឬដោយបញ្ញត្តិ ត្រូវសម្រេចដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី។

ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សនេះមិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិលើកសំណើមកក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យសម្រេចតាមនីតិវិធីជាធរមាន។

**មាត្រា៤៧ .-**

ទិវាពលកម្មអន្តរជាតិ ១ឧសភា នាឆ្នាំនេះ ប្រារព្ធឡើងក្រោមប្រធានបទ **«លើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈ និងស្ថិរភាពផលិតកម្ម ដើម្បីបង្កើនផលិតភាព និងការងារ»** សំដៅពង្រឹងភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ការធានាបាននូវស្ថិរភាពវិនិយោគ ភាពប្រកួតប្រជែង និងគុណភាពផលិតផល ព្រមទាំងការកែលម្អជីវភាពរបស់កម្មករនិយោជិត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។

ដើម្បីរៀបចំការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣០ នៃទិវាពលកម្មអន្តរជាតិ១ឧសភា ឆ្នាំ២០១៦ ឱ្យប្រព្រឹត្តទៅបានល្អប្រសើរថែមទៀត រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំដូចខាងក្រោម៖

១-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើជាស្ថាប័នស្នូលក្នុងការរៀបចំទិវាអន្តរជាតិនេះ ដោយចេញសេចក្តីជូនដំណឹងដល់គ្រប់មន្ទីររាជធានី-ខេត្តក្រោមឱវាទ អង្គការវិជ្ជាជីវៈរបស់និយោជក ម្ចាស់និងនាយកសហគ្រាស គ្រឹះស្ថានអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ព្រមទាំងកម្មករនិយោជិតទាំងអស់ ដើម្បីណែនាំអំពីការឈប់សម្រាក និងការរៀបចំកម្មវិធីកម្សាន្តសប្បាយតាមលទ្ធភាពរៀងៗខ្លួននៅតាមសហគ្រាស និងគ្រឹះស្ថាននានា សំដៅបង្កបរិយាកាសយោគយល់គ្នារវាងកម្មករ និយោជិត និងនិយោជក។ ទន្ទឹមនឹងនេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំពិធីមិទ្ទីញថ្នាក់ជាតិ ដែលមានការចូលរួមពីតំណាងក្រសួងស្ថាប័នរដ្ឋ តំណាងអង្គការវិជ្ជាជីវៈ តំណាងអង្គការជាតិនិងអន្តរជាតិដែលជាដៃគូ។ ជាមួយគ្នានេះ គណៈអភិបាលរាជធានីខេត្តទាំងអស់ត្រូវចាត់តាំងរៀបចំពិធីសំណេះសំណាលជាមួយតំណាងកម្មករ និយោជិត នៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន តាមស្ថានភាពជាក់ស្តែង។

២-ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរដែនដីរាជធានីខេត្ត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធានារក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ក្នុងឱកាសនៃការប្រារព្ធទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៦ នេះ។

៣-ក្រសួងព័ត៌មាន ត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជនឱ្យធ្វើការផ្សព្វផ្សាយសារលិខិតរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣០ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា និងសកម្មភាពមិទ្ទីញ ការកម្សាន្តសប្បាយនានា របស់កម្មករ និយោជិត និងនិយោជក នៅតាមសហគ្រាស និងគ្រឹះស្ថាននានា។

៤-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កលក្ខណៈងាយស្រួលក្នុងការផ្តល់ថវិកា សម្រាប់ការរៀបចំប្រារព្ធទិវាពលកម្មអន្តរជាតិ ១ឧសភានេះ។

៥-រាជធានីភ្នំពេញ និងខេត្តទាំងអស់ ក៏ដូចជាក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាស គ្រឹះស្ថានឯកជន ត្រូវជ្រើសរើសទីតាំងសមស្រប ដូចជា ដងវិថីសំខាន់ៗ និងទីតាំងសហគ្រាស គ្រឹះស្ថាន ការដ្ឋាន និងកសិដ្ឋាន ដើម្បីធ្វើការចងបដាពាក្យស្លោកតាមខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣០ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា
- លើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈ និងស្ថិរភាពផលិតកម្ម ដើម្បីបង្កើនផលិតភាពនិងការងារ
- ខិតខំកសាងភាពសុខដុមរមនា រវាងនិយោជក និងកម្មករ និយោជិតនៅតាមសហគ្រាស និងគ្រឹះស្ថាន។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និយោជក កម្មករ និយោជិតកម្ពុជា និងពលករបរទេសទាំងអស់ ចូលរួមប្រារព្ធនិងអបអរសាទរទិវាពលកម្មអន្តរជាតិ ១ឧសភា ក្នុងបរិយាកាសសោមនស្សរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមជាបុណ្យការងាររបស់ជាតិយើង។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានីខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៤៧ សរណន

# សារាចរណែនាំ
# ស្តីពី
# ការគ្រប់គ្រងរថយន្តនាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ និងការកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

នាពេលកន្លងមក រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រសួង-ស្ថាប័នរដ្ឋ និងបុគ្គលពាក់ព័ន្ធនាំចូលរថយន្ត សម្រាប់បម្រើការងារ ដែលជាប្រភេទទំនិញមានវេទយិតភាពខ្ពស់ រួមចំណែកយ៉ាងសំខាន់ក្នុងចំណូលពន្ធ និងអាករគយដែលជាប្រភពចំណូលដ៏ចំបងនៃថវិកាជាតិ ដោយដាក់ពន្ធអាករជាបន្ទុករបស់រដ្ឋ ប៉ុន្តែមានករណីខ្លះការប្រើប្រាស់រថយន្តទាំងនោះមិនទាន់ចំគោលដៅ និងធានាបាននូវប្រសិទ្ធភាពពេញលេញ រីឯការកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋក៏មិនទាន់បានសព្វគ្រប់អស់នៅឡើយ។

អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨, ច្បាប់ស្តីពីគយ ឆ្នាំ២០០៧, ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ និងវិសោធនកម្មច្បាប់ជាបន្តបន្ទាប់, សារាចរលេខ ០៧.សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៤ របស់រាជរដ្ឋាភិបាល និងក្នុងគោលដៅពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងរថយន្តគ្រប់ប្រភេទរបស់ក្រសួង-ស្ថាប័នរដ្ឋ និងបុគ្គលពាក់ព័ន្ធដែលបានអនុញ្ញាតឱ្យនាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ រាជរដ្ឋាភិបាល សូមធ្វើការណែនាំ និងដាក់វិធានការឱ្យអនុវត្តដូចខាងក្រោម÷

### ១. អំពីពន្ធនិងអាករនាំចូល

- ការនាំចូលរថយន្តរបស់ក្រសួង-ស្ថាប័នរដ្ឋ និងបុគ្គលពាក់ព័ន្ធ ដែលអាចទទួលបានការបង់ពន្ធអាករជាបន្ទុករបស់រដ្ឋ ត្រូវសុំការអនុញ្ញាតយល់ព្រមជាមុនពីរាជរដ្ឋាភិបាល។ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ឱ្យនាំចូលរថយន្ត ដោយពន្ធអាករជាបន្ទុករបស់រដ្ឋ រថយន្តទាំងនោះត្រូវបំពេញបែបបទនាំចូលដោយស្របច្បាប់

- ការនាំចូលរថយន្តរបស់អង្គទូត អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ជាមធ្យោបាយចាំបាច់បំពេញការងារត្រូវអនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិ, កិច្ចព្រមព្រៀងក្របខ័ណ្ឌរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃប្រទេសដៃគូអភិវឌ្ឍន៍ ឬអង្គការអន្តរជាតិ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវបន្តពង្រឹងយន្តការគ្រប់គ្រងលើរថយន្តដែលទទួលបានគោលការណ៍ពន្ធអាករជាបន្ទុករបស់រដ្ឋ តាមរយៈការបិតលតាប័ត្រ (Vignette) ដោយឡែក
- **ការធ្វើអំណោយជារថយន្តពីប្រភពក្នុងនិងក្រៅប្រទេស** ជូនក្រសួង-ស្ថាប័នរដ្ឋអាចធ្វើទៅបាន លុះត្រាតែរថយន្តទាំងនោះត្រូវបាននាំចូលដោយស្របច្បាប់ និងបានបំពេញកាតព្វកិច្ចពន្ធអាករតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន លើកលែងតែមានការអនុញ្ញាតដោយឡែកពីរាជរដ្ឋាភិបាល។

### ២. អំពីការចុះបញ្ជីរថយន្តជាទ្រព្យសម្បត្តិរដ្ឋ

- គ្រប់ក្រសួង-ស្ថាប័នរដ្ឋដែលទិញ និងនាំចូលរថយន្តដោយបង់ពន្ធអាករតាមច្បាប់ជាធរមានត្រូវកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- គ្រប់ក្រសួង-ស្ថាប័នរដ្ឋ និងបុគ្គលពាក់ព័ន្ធដែលទទួលបានការអនុញ្ញាតឱ្យនាំចូលរថយន្តដោយស្របច្បាប់ដោយពន្ធអាករជាបន្ទុករបស់រដ្ឋត្រូវកត់ត្រារថយន្តទាំងនោះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ លើកលែងតែករណីមន្ត្រីជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ត្រឡប់មកពីបំពេញបេសកកម្មរយៈពេលវែងនៅក្រៅប្រទេស ដែលត្រូវបានកំណត់ក្នុងបទប្បញ្ញត្តិដោយឡែករួចហើយ
- បញ្ជីសារពើភណ្ឌត្រូវបញ្ជូន ១ច្បាប់ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ)។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំយន្តការចែករំលែកព័ត៌មានរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដើម្បីពង្រឹងការគ្រប់គ្រងរថយន្តស្ថិតក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ការចុះបញ្ជីផ្តល់ប័ណ្ណសំគាល់រថយន្ត និងផ្លាកលេខសម្គាល់រថយន្តដែលជាទ្រព្យសម្បត្តិរដ្ឋ ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធអាចធ្វើទៅបាន លុះត្រាតែរថយន្តទាំងនោះត្រូវបាននាំចូលដោយស្របច្បាប់ និងបានបំពេញកាតព្វកិច្ចពន្ធអាករតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

### ៣. អំពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

- រថយន្តដែលជាទ្រព្យសម្បត្តិរដ្ឋនឹងត្រូវបានអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទបាន លុះត្រាតែរថយន្តនោះត្រូវបាននាំចូលដោយស្របច្បាប់ និងបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

- រថយន្តដែលកត់ត្រាចូលបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបំពេញកាតព្វកិច្ចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- រថយន្តដែលកត់ត្រាចូលបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ អាចទទួលបានការអនុញ្ញាតលើកលែងពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំបាន លុះត្រាតែរថយន្តនោះមានលក្ខណៈសម្បត្តិស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**៤. អំពីការទិញរថយន្តដោយប្រើប្រាស់ថវិការដ្ឋ**

- ការទិញរថយន្តដោយប្រើប្រាស់ថវិការដ្ឋ ដើម្បីជាមធ្យោបាយចាំបាច់បំពេញការងាររដ្ឋ ត្រូវសុំការអនុញ្ញាតជាគោលការណ៍ជាមុនពីរាជរដ្ឋាភិបាល និងត្រូវមានគ្រោងក្នុងឥណទានថវិកាប្រចាំឆ្នាំ
- ចាប់ពីឆ្នាំ២០១៧ តទៅ សំណើសុំទិញរថយន្តដោយប្រើប្រាស់ថវិការដ្ឋរបស់ក្រសួង-ស្ថាប័ន ត្រូវរួមបញ្ចូលឱ្យហើយនូវពន្ធនិងអាករគ្រប់ប្រភេទ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន សាលារាជធានី-ខេត្ត និងនីតិបុគ្គលសាធារណៈដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ*
*-គ្រប់សាលារាជធានី ខេត្ត*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០៤៤៤...សហវ.ហក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វាន់ឧបករណ៍ប្រធានសម្រាប់ឆ្នាំ ២០១៦
## របស់ក្រសួងផែនការ

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួងខេត្តក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិកា របស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ៦០ "ការទិញ" និង ជំពូក ៦១ "សេវាកម្ម" នៅក្រសួងផែនការសម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទានត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុនៃក្រសួងផែនការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងផែនការត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៦

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួង ផែនការ**

**តារាងឧបសម្ព័ន្ធវដ្តទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធីឆ្នាំ ២០១៦**

**របស់ក្រសួង ផែនការ** ✓

(រដ្ឋបាលកណ្តាល)

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន វដ្តទេយ្យបុរេប្រទាន 30% | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិល វដ្តទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៦ជុំ | ៦=៣/២ |
| សរុបរួម | | | ជំពូក ៦០ + ៦១ | 20 368 000 000 | 5 406 000 000 | 589 440 000 | 4 816 560 000 | 98 240 000 | 10,90% |
| 60 | | | ការទិញ | 7 628 000 000 | 3 148 000 000 | 169 800 000 | 2 978 200 000 | 28 300 000 | 5,39% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 2 150 000 000 | 50 000 000 | 49 800 000 | 200 000 | 8 300 000 | 99,60% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ | 16 000 000 | 16 000 000 | 15 900 000 | 100 000 | 2 650 000 | 99,38% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ | 16 000 000 | 16 000 000 | 15 900 000 | 100 000 | 2 650 000 | 99,38% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 18 000 000 | 18 000 000 | 18 000 000 | 0 | 3 000 000 | 100,00% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 2 100 000 000 | 0 | 0 | 0 | 0 | 0,00% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 3 107 000 000 | 3 098 000 000 | 120 000 000 | 2 978 000 000 | 20 000 000 | 3,87% |
| | | 60021 | សម្ភារៈការិយាល័យ និងបោះពុម្ព | 3 098 000 000 | 3 098 000 000 | 120 000 000 | 2 978 000 000 | 20 000 000 | 3,87% |
| | | 60022 | សៀវភៅមើល និងឯកសារ | 9 000 000 | 0 | 0 | 0 | 0 | 0,00% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 1 750 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 60051 | សម្ភារៈ និងបរិក្ខារបច្ចេកទេស | 1 000 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 60052 | សង្ហារឹម | 750 000 000 | 0 | 0 | 0 | 0 | 0,00% |
| | 6006 | | ថាមពល និងទឹក | 621 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 60061 | អគ្គីសនី | 581 000 000 | 0 | 0 | 0 | 0 | 0,00% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 60062 | ទឹក | 40 000 000 | 0 | 0 | 0 | 0 | 0,00% |
| 61 | | | សេវាខាងក្រៅ | 12 740 000 000 | 2 258 000 000 | 419 640 000 | 1 838 360 000 | 69 940 000 | 18,58% |
| | 6101 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | 1 970 000 000 | 0 | 0 | 0 | 0 | 0,00% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 67 000 000 | 0 | 0 | 0 | 0 | 0,00% |
| | 6105 | | ការថែទាំ និងជួសជុល | 640 000 000 | 640 000 000 | 99 900 000 | 540 100 000 | 16 650 000 | 15,61% |
| | | 61052 | ការថែទាំ និងជួសជុលអគារផ្សេងៗ និងប្រាសាទ | 600 000 000 | 600 000 000 | 60 000 000 | 540 000 000 | 10 000 000 | 10,00% |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 16 000 000 | 16 000 000 | 15 900 000 | 100 000 | 2 650 000 | 99,38% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈនិងឧបករណ៍បច្ចេកទេស | 24 000 000 | 24 000 000 | 24 000 000 | 0 | 4 000 000 | 100,00% |
| | 6110 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | 1 612 000 000 | 1 612 000 000 | 313 980 000 | 1 298 020 000 | 52 330 000 | 19,48% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 24 000 000 | 24 000 000 | 24 000 000 | 0 | 4 000 000 | 100,00% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 350 000 000 | 350 000 000 | 72 000 000 | 278 000 000 | 12 000 000 | 20,57% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសិទ្ធ | 1 120 000 000 | 1 120 000 000 | 150 000 000 | 970 000 000 | 25 000 000 | 13,39% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 8 000 000 | 8 000 000 | 7 980 000 | 20 000 | 1 330 000 | 99,75% |
| | | 61105 | ការទិញវត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស | 110 000 000 | 110 000 000 | 60 000 000 | 50 000 000 | 10 000 000 | 54,55% |
| | 6111 | | ចំណាយលើការជាវសារព័ត៌មាននិងឯកសារ | 16 000 000 | 6 000 000 | 5 760 000 | 240 000 | 960 000 | 96,00% |
| | | 61113 | ចំណាយលើការជាវសៀវភៅរាជកិច្ច | 10 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 61118 | ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ | 6 000 000 | 6 000 000 | 5 760 000 | 240 000 | 960 000 | 96,00% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 7 582 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 150 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 61122 | សោហ៊ុយបេសកកម្ម | 2 090 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 5 342 000 000 | 0 | 0 | 0 | 0 | 0,00% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 742 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 185 000 000 | 0 | 0 | 0 | 0 | 0,00% |
| | | 61132 | សោហ៊ុយបេសកកម្ម | 370 000 000 | 0 | 0 | 0 | 0 | 0,00% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61133 | សោហ៊ុយស្នាក់នៅ និងហូបចុក | 187 000 000 | 0 | 0 | 0 | 0 | 0,00% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | **111 000 000** | **0** | **0** | **0** | **0** | 0,00% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 111 000 000 | 0 | 0 | 0 | 0 | 0,00% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ភ្នំពេញ, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៦
ជ. **អគ្គនាយក**
**អគ្គនាយកដ្ឋានរតនាគារជាតិ**
**អគ្គនាយករង**

**ម៉ិញ ប៉ានសុវណ្ណអានិច្ចាស៊ីលា**

បានឃើញនិងពិនិត្យត្រឹមត្រូវ
ភ្នំពេញ, ថ្ងៃទី ១០ ខែ ០២ ឆ្នាំ ២០១៦
**អគ្គនាយក**
ជ. **អគ្គនាយកដ្ឋានថវិកា**

បានឃើញនិងឯកភាព
ភ្នំពេញ, ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

បានឃើញនិងពិនិត្យត្រឹមត្រូវ
ភ្នំពេញ, ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១៦
**ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ**

**ស្រី_និមល**

ភ្នំពេញ, ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១៦
**រដ្ឋលេខាធិការប្រចាំក្រសួង**

**វ៉ា_ស៊ីនាង**

បានឃើញនិងឯកភាព
ភ្នំពេញ, ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១៦
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ផែនការ**

**ឆាយ ថន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១៣៧......សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការបង្កើតនិងតែងតាំងក្រុមលទ្ធកម្ម**
**របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តឧត្តរមានជ័យ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិការកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាស ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- បានឃើញប្រកាស ៥៥៨ សហវ.ប្រក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងតែងតាំងក្រុមលទ្ធកម្មនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- បានឃើញប្រកាសលេខ ១៨៤២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតនិងតែងតាំងក្រុមលទ្ធកម្មនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តឧត្តរមានជ័យ ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. លោក **រស់ ផល្លា** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តឧត្តរមានជ័យ | ជាប្រធាន |
| ២. លោក **ទ្រឿង ប្រុសិទ្ធ** | អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តឧត្តរមានជ័យ | ជាអនុប្រធាន |
| ៣. លោក **ឡើត ម៉ុណ្ណារិទ្ធ** | ប្រធានការិយាល័យលទ្ធកម្មសាធារណៈ | ជាសមាជិក |
| ៤. លោកស្រី **ហ៊ីង ផានិត** | មន្ត្រីការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ | ជាសមាជិក។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៧៥...សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតវិទ្យាល័យបុរេប្រទានសម្រាប់ឆ្នាំ២០១៦ របស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

(ទំព័រទី១)

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ ៤ ប្រការ ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៦២ អយក.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១ ៖-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក ៦៤ "បន្ទុកបុគ្គលិក" , នៅនាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មីនៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ។

**ប្រការ ២ ៖-**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាម ភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមិនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ

ទំព័រទី២)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អង្គភាពថវិកានាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន
## ថវិកាកម្មវិធីឆ្នាំ២០១៦ របស់អង្គភាពថវិកានាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | ពាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទានទំហំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | | | សរុប | 4,360,300,000 | 4,351,300,000 | 1,258,800,000 | 3,092,500,000 | 314,700,000 | 28.9% |
| 60 | | | ការទិញ | 3,138,800,000 | 3,138,800,000 | 123,800,000 | 3,015,000,000 | 30,950,000 | 3.9% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 8,000,000 | 8,000,000 | 8,000,000 | - | 2,000,000 | 100.0% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 6,000,000 | 6,000,000 | 6,000,000 | - | 1,500,000 | 100.0% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 2,589,000,000 | 2,589,000,000 | 74,000,000 | 2,515,000,000 | 18,500,000 | 2.9% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 2,585,000,000 | 2,585,000,000 | 70,000,000 | 2,515,000,000 | 17,500,000 | 2.7% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 4,000,000 | 4,000,000 | 4,000,000 | - | 1,000,000 | 100.0% |
| | 6003 | | ស្បៀងអាហារនិងផលិតផលកសិកម្ម | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 60031 | ស្បៀង | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 531,800,000 | 531,800,000 | 31,800,000 | 500,000,000 | 7,950,000 | 6.0% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 522,400,000 | 522,400,000 | 22,400,000 | 500,000,000 | 5,600,000 | 4.3% |
| | | 60052 | សង្ហារឹម | 1,500,000 | 1,500,000 | 1,500,000 | - | 375,000 | 100.0% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 6,700,000 | 6,700,000 | 6,700,000 | - | 1,675,000 | 100.0% |
| | | 60058 | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ | 1,200,000 | 1,200,000 | 1,200,000 | - | 300,000 | 100.0% |
| 61 | | | សេវាកម្ម | 1,194,400,000 | 1,193,400,000 | 1,115,900,000 | 77,500,000 | 278,975,000 | 93.5% |
| | 6101 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | 1,000,000 | - | - | | - | #DIV/0! |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100.0% |
| | 6105 | | ការថែទាំនិងជួសជុល | 40,000,000 | 40,000,000 | 40,000,000 | - | 10,000,000 | 100.0% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.0% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 12,000,000 | 12,000,000 | 12,000,000 | - | 3,000,000 | 100.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 8,000,000 | 8,000,000 | 8,000,000 | - | 2,000,000 | 100.0% |
| | 6109 | | បុគ្គលិកខាងក្រៅ | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | | 61098 | បុគ្គលិកខាងក្រៅផ្សេងៗ | 2,000,000 | 2,000,000 | 2,000,000 | - | 500,000 | 100.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 231,200,000 | 231,200,000 | 161,200,000 | 70,000,000 | 40,300,000 | 69.7% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 217,000,000 | 217,000,000 | 147,000,000 | 70,000,000 | 36,750,000 | 67.7% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 14,200,000 | 14,200,000 | 14,200,000 | - | 3,550,000 | 100.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 889,000,000 | 889,000,000 | 889,000,000 | - | 222,250,000 | 100.0% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 177,600,000 | 177,600,000 | 177,600,000 | - | 44,400,000 | 100.0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 97,600,000 | 97,600,000 | 97,600,000 | - | 24,400,000 | 100.0% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 613,800,000 | 613,800,000 | 613,800,000 | - | 153,450,000 | 100.0% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 11,200,000 | 11,200,000 | 11,200,000 | - | 2,800,000 | 100.0% |
| | | 61132 | សោហ៊ុយបេសកកម្ម | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.0% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 1,200,000 | 1,200,000 | 1,200,000 | - | 300,000 | 100.0% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 10,000,000 | 10,000,000 | 2,500,000 | 7,500,000 | 625,000 | 25.0% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 10,000,000 | 10,000,000 | 2,500,000 | 7,500,000 | 625,000 | 25.0% |

| ជំពូក | គណនី | អនុគណនី | ការបរិយាយចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន វដ្តទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ជុំបង្វិល វដ្តទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| 64 | | | បន្ទុកបុគ្គលិក | 27,100,000 | 19,100,000 | 19,100,000 | - | 4,775,000 | 100.0% |
| | 6403 | | វេតនៈ និងប្រាក់បំណាច់ផ្សេងៗ | 19,100,000 | 19,100,000.00 | 19,100,000.00 | - | 4,775,000.00 | 100.0% |
| | | 64038 | ប្រាក់បំណាច់ផ្សេងៗ | 19,100,000 | 19,100,000 | 19,100,000 | - | 4,775,000.00 | 100.0% |
| | 6405 | | ប្រាក់វិភាគទានសង្គមសម្រាប់មន្ត្រីរាជការ | 8,000,000 | - | - | - | - | #DIV/0! |
| | | 64051 | មន្ត្រីមានជំងឺ | 4,000,000 | - | | - | - | #DIV/0! |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារនិងទុព្វលភាព | 4,000,000 | - | | - | - | #DIV/0! |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី២៦ ខែ[illegible] ឆ្នាំ២០១៦
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
មិញ បានសុវណ្ណអានិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៦
ជ.អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា
ប៊ូ_ច័ន្ទបូរ៉ា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦
ប្រធានអង្គភាពថវិកា
នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
គួច_គួលំអ

ថ្ងៃទី០១ខែកុម្ភៈ ឆ្នាំ២០១៦
វដ្តទេយ្យករបុរេប្រទាន
គ្រួច_លក្ខិណា

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៦
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៦
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
បណ្ឌិត ហង់ ជួន ណារ៉ុន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៦៧៩ សហវ.ប្រ.ក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតវិជ្ជាបនបត្រទេយ្យបុរេប្រទាន នៅទីស្តីការគណៈរដ្ឋមន្ត្រី

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីកាកែសម្រួលនិងបំពេញបន្ថែមសមាភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
- បានឃើញអនុក្រឹត្យលេខ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩ សហវ.ម.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ២១១ សហវ.ម.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ១៩៣៧ សហវ.ម.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ម.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីស្តីការគណៈរដ្ឋមន្ត្រី

<u>**សម្រេច**</u>

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០"ការទិញ" ជំពូក៦១"សេវាកម្ម" ជំពូក៦២"អត្ថប្រយោជន៍សង្គម" និងជំពូក៦៥"ឧបត្ថម្ភកធន" នៅទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ម.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ។ ដោយឡែកចំពោះចំណាយពិសេសរបស់រាជរដ្ឋាភិបាល អាចធ្វើប័ណ្ណចំណាយលើសពីចំនួន ១.៥០០.០០០៛ (មួយលាន ប្រាំរយពាន់រៀល)។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទានត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ២០១៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

## តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ឆ្នាំ២០១៦
## របស់ទីស្តីការគណៈរដ្ឋមន្ត្រី

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន០១ដុំបង្វិលរជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | **សរុបរួម** | 263.941.000.000 | 138.714.000.000 | 35.157.900.000 | 103.556.100.000 | 5.859.650.000 | 25,35% |
| | | | **ប្រភេទទី១: មធ្យោបាយ និងសេវា** | 63.317.000.000 | 31.590.000.000 | 6.630.900.000 | 24.959.100.000 | 1.105.150.000 | 20,99% |
| 60 | | | **ការទិញ** | 32.405.000.000 | 9.705.000.000 | 2.910.000.000 | 6.795.000.000 | 485.000.000 | 29,98% |
| | 6001 | | **សម្ភារៈផ្គត់ផ្គង់ថែទាំ** | 5.155.000.000 | 1.855.000.000 | 630.000.000 | 1.225.000.000 | 105.000.000 | 33,96% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់ សំអាត និង អនាម័យ | 705.000.000 | 705.000.000 | 192.000.000 | 513.000.000 | 32.000.000 | 27,23% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអាគារ | 500.000.000 | 500.000.000 | 186.000.000 | 314.000.000 | 31.000.000 | 37,20% |
| | | 60013 | សំភារៈផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាននិងលូ | 500.000.000 | 500.000.000 | 186.000.000 | 314.000.000 | 31.000.000 | 37,20% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 150.000.000 | 150.000.000 | 66.000.000 | 84.000.000 | 11.000.000 | 44,00% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 3.300.000.000 | | | | | |
| | 6002 | | **សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល** | 2.600.000.000 | 2.600.000.000 | 786.000.000 | 1.814.000.000 | 131.000.000 | 30,23% |
| | | 60021 | សម្ភារៈការិយាល័យ និងការបោះពុម្ព | 2.500.000.000 | 2.500.000.000 | 750.000.000 | 1.750.000.000 | 125.000.000 | 30,00% |
| | | 60022 | សៀវភៅមើល និងឯកសារ | 100.000.000 | 100.000.000 | 36.000.000 | 64.000.000 | 6.000.000 | 36,00% |
| | 6004 | | **សំលៀកបំពាក់ និង ការតុបតែង** | 4.850.000.000 | 450.000.000 | 84.000.000 | 366.000.000 | 14.000.000 | 18,67% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 60041 | ឯកសណ្ឋាន | 350.000.000 | 350.000.000 | 24.000.000 | 326.000.000 | 4.000.000 | 6,86% |
| | | 60042 | សំលៀកបំពាក់ការពារសុវត្ថិភាព | 100.000.000 | 100.000.000 | 60.000.000 | 40.000.000 | 10.000.000 | 60,00% |
| | | 60043 | មេដាយ (គ្រឿងឥស្សរិយយស) | 4.400.000.000 | | | | | |
| | 6005 | | **សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ** | 4.800.000.000 | 4.800.000.000 | 1.410.000.000 | 3.390.000.000 | 235.000.000 | 29,38% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 1.900.000.000 | 1.900.000.000 | 570.000.000 | 1.330.000.000 | 95.000.000 | 30,00% |
| | | 60052 | សង្ហារឹម | 1.400.000.000 | 1.400.000.000 | 240.000.000 | 1.160.000.000 | 40.000.000 | 17,14% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 600.000.000 | 600.000.000 | 240.000.000 | 360.000.000 | 40.000.000 | 40,00% |
| | | 60058 | សម្ភារៈតូចតាច សង្ហារឹមនិងសម្ភារៈបរិក្ខារផ្សេងៗ | 900.000.000 | 900.000.000 | 360.000.000 | 540.000.000 | 60.000.000 | 40,00% |
| | 6006 | | ថាមពល និងទឹក | 15.000.000.000 | | | | | |
| | | 60061 | អគ្គិសនី | 14.600.000.000 | | | | | |
| | | 60062 | ទឹក | 400.000.000 | | | | | |
| 61 | | | **សេវាកម្ម** | 30.912.000.000 | 21.885.000.000 | 3.720.900.000 | 18.164.100.000 | 620.150.000 | 17,00% |
| | 6101 | | កិច្ចសន្យានៃការផ្ដល់សេវាជាមួយសហគ្រាស | 1.600.000.000 | 1.600.000.000 | 60.000.000 | 1.540.000.000 | 10.000.000 | 3,75% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 80.000.000 | 80.000.000 | 36.000.000 | 44.000.000 | 6.000.000 | 45,00% |
| | 6103 | | ការជួលផ្ទះជួលអាគារសម្រាប់អោយមន្ត្រីការទូតនៅក្រៅប្រទេស | 230.000.000 | | | | | |
| | 6105 | | **ការថែទាំ និងជួសជុល** | 6.400.000.000 | 6.000.000.000 | 1.179.900.000 | 4.820.100.000 | 196.650.000 | 19,67% |
| | | 61052 | ការថែទាំជួសជុលអាគារផ្សេងៗ និងប្រាសាទ | 400.000.000 | | | | | |
| | | 61053 | ការថែទាំនិងជួសជុលស្ពាន លូ ផ្លូវលំ ផ្លូវ | 200.000.000 | 200.000.000 | 99.900.000 | 100.100.000 | 16.650.000 | 49,95% |
| | | 61054 | ការថែទាំបណ្ដាញផ្សេងៗ | 1.200.000.000 | 1.200.000.000 | 300.000.000 | 900.000.000 | 50.000.000 | 25,00% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61056 | ការថែទាំ និង ជួសជុលមធ្យោបាយដឹកជញ្ជូន | 600.000.000 | 600.000.000 | 240.000.000 | 360.000.000 | 40.000.000 | 40,00% |
| | | 61057 | ការថែទាំ និងជួសជុលសម្ភារៈឧបករណ៍បច្ចេកទេស | 700.000.000 | 700.000.000 | 240.000.000 | 460.000.000 | 40.000.000 | 34,29% |
| | | 61058 | ការថែទាំ និងជួសជុលផ្សេងៗ | 3.300.000.000 | 3.300.000.000 | 300.000.000 | 3.000.000.000 | 50.000.000 | 9,09% |
| | **6109** | | បុគ្គលិកខាងក្រៅ | 1.222.000.000 | | | | | |
| | | 61092 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា | 1.222.000.000 | | | | | |
| | **6110** | | **ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ** | 8.550.000.000 | 8.550.000.000 | 1.716.000.000 | 6.834.000.000 | 286.000.000 | 20,07% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 2.000.000.000 | 2.000.000.000 | 402.000.000 | 1.598.000.000 | 67.000.000 | 20,10% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 2.600.000.000 | 2.600.000.000 | 390.000.000 | 2.210.000.000 | 65.000.000 | 15,00% |
| | | 61103 | ប្រជុំ-សិក្ខាសាលា សន្និសីទ | 350.000.000 | 350.000.000 | 144.000.000 | 206.000.000 | 24.000.000 | 41,14% |
| | | 61104 | ចំណាយរៀបពិធីបុណ្យ | 2.000.000.000 | 2.000.000.000 | 300.000.000 | 1.700.000.000 | 50.000.000 | 15,00% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស | 1.600.000.000 | 1.600.000.000 | 480.000.000 | 1.120.000.000 | 80.000.000 | 30,00% |
| | **6111** | | **ចំណាយលើការជាវសារព័ត៌មាននិងឯកសារ** | 280.000.000 | 105.000.000 | 51.000.000 | 54.000.000 | 8.500.000 | 48,57% |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 110.000.000 | | | | | |
| | | 61112 | ចំណាយលើការជាវទស្សនាវដ្ដី | 20.000.000 | 20.000.000 | 15.000.000 | 5.000.000 | 2.500.000 | 75,0% |
| | | 61113 | ចំណាយលើការជាវសៀវភៅរាជកិច្ច | 65.000.000 | | | | | |
| | | 61118 | ចំណាយលើការជាវសារព័ត៌មាននិងឯកសារផ្សេងៗ | 85.000.000 | 85.000.000 | 36.000.000 | 49.000.000 | 6.000.000 | 42,35% |
| | **6112** | | **ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស** | 1.450.000.000 | 1.450.000.000 | 588.000.000 | 862.000.000 | 98.000.000 | 40,55% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 300.000.000 | 300.000.000 | 120.000.000 | 180.000.000 | 20.000.000 | 40,00% |
| | | 61122 | សោហ៊ុយបេសកកម្ម | 200.000.000 | 200.000.000 | 78.000.000 | 122.000.000 | 13.000.000 | 39,00% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61123 | សោហ៊ុយស្នាក់នៅ | 950.000.000 | 950.000.000 | 390.000.000 | 560.000.000 | 65.000.000 | 41,05% |
| | 6113 | | **ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស** | 8.000.000.000 | 1.000.000.000 | 48.000.000 | 952.000.000 | 8.000.000 | 4,80% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 3.400.000.000 | | | | | |
| | | 61132 | សោហ៊ុយបេសកកម្ម | 1.000.000.000 | 1.000.000.000 | 48.000.000 | 952.000.000 | 8.000.000 | 4,80% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 3.600.000.000 | | | | | |
| | 6114 | | **សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍** | 3.100.000.000 | 3.100.000.000 | 42.000.000 | 3:058.000.000 | 7.000.000 | 1,35% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 50.000.000 | 50.000.000 | 12.000.000 | 38.000.000 | 2.000.000 | 24,00% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 3.050.000.000 | 3.050.000.000 | 30.000.000 | 3.020.000.000 | 5.000.000 | 0,98% |
| **ប្រភេទទី៣ អន្តរាគមន៍សាធារណៈ** | | | | 200.624.000.000 | 107.124.000.000 | 28.527.000.000 | 78.597.000.000 | 4.754.500.000 | 26,63% |
| 62 | | | **អត្ថប្រយោជន៍សង្គម** | 65.200.000.000 | 62.000.000.000 | 18.000.000.000 | 44.000.000.000 | 3.000.000.000 | 29,03% |
| | 6202 | | ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 65.200.000.000 | 62.000.000.000 | 18.000.000.000 | 44.000.000.000 | 3.000.000.000 | 29,03% |
| | | 62024 | ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ | 2.500.000.000 | | | | | |
| | | 62025 | អាហារូបករណ៍សម្រាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស | 700.000.000 | | | | | |
| | | 62028 | ជំនួយសង្គមផ្សេងៗទៀត | 62.000.000.000 | 62.000.000.000 | 18.000.000.000 | 44.000.000.000 | 3.000.000.000 | 29,03% |
| | | | ចំណាយពិសេសរបស់រាជរដ្ឋាភិបាល | 50.000.000.000 | 50.000.000.000 | 17.880.000.000 | 32.120.000.000 | 2.980.000.000 | 35,76% |
| | | | អង្គភាពអាកាសចររាជរដ្ឋាភិបាល | 12.000.000.000 | 12.000.000.000 | 120.000.000 | 11.880.000.000 | 20.000.000 | 1,00% |
| 65 | | | **ឧបត្ថម្ភធន** | 135.424.000.000 | 45.124.000.000 | 10.527.000.000 | 34.597.000.000 | 1.754.500.000 | 23,33% |
| | 6502 | | ឧបត្ថម្ភធនដល់អង្គការសាធារណៈ | 47.124.000.000 | 37.824.000.000 | 8.961.000.000 | 28.863.000.000 | 1.493.500.000 | 23,69% |
| | | 65021 | **ឧបត្ថម្ភធនដល់អង្គការដែលមានលក្ខណៈសេដ្ឋកិច្ច** | 1.800.000.000 | 1.800.000.000 | 432.000.000 | 1.368.000.000 | 72.000.000 | 24,00% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | ១-ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | 1.350.000.000 | 1.350.000.000 | 324.000.000 | 1.026.000.000 | 54.000.000 | 24,00% |
| | | | គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ | 450.000.000 | 450.000.000 | 108.000.000 | 342.000.000 | 18.000.000 | 24,00% |
| | | 65022 | **ឧបត្ថម្ភធនដល់អង្គការដែលមានលក្ខណៈសង្គម** | 2.749.000.000 | 2.749.000.000 | 840.000.000 | 1.909.000.000 | 140.000.000 | 30,56% |
| | | | ១-គណៈកម្មាធិការសិទ្ធមនុស្សកម្ពុជា | 550.000.000 | 550.000.000 | 165.000.000 | 385.000.000 | 27.500.000 | 30,00% |
| | | | ២-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | 1.699.000.000 | 1.699.000.000 | 495.000.000 | 1.204.000.000 | 82.500.000 | 29,13% |
| | | | ៣-គណៈកម្មការស្រាវជ្រាវជីករុករកអដ្ឋិធាតុជនជាតិ អាមេរិក និងកងទ័ពវៀតណាមដែលបាត់ខ្លួននៅកម្ពុជា | 500.000.000 | 500.000.000 | 180.000.000 | 320.000.000 | 30.000.000 | 36,00% |
| | | 65023 | **ឧបត្ថម្ភធនដល់អង្គការដែលមានលក្ខណៈអប់រំនិងកីឡា** | 2.100.000.000 | 2.100.000.000 | 540.000.000 | 1.560.000.000 | 90.000.000 | 25,71% |
| | | | ១-ក្រុមប្រឹក្សាជាតិភាសាខ្មែរ | 1.000.000.000 | 1.000.000.000 | 210.000.000 | 790.000.000 | 35.000.000 | 21,00% |
| | | | ២-កាយរឹទ្ធិជាតិកម្ពុជា | 1.100.000.000 | 1.100.000.000 | 330.000.000 | 770.000.000 | 55.000.000 | 30,00% |
| | | 65024 | **ឧបត្ថម្ភធនដល់អង្គការដែលមានលក្ខណៈសន្តិសុខសង្គម** | 35.575.000.000 | 26.275.000.000 | 5.637.000.000 | 20.638.000.000 | 939.500.000 | 21,45% |
| | | | ១-អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | 600.000.000 | 600.000.000 | 180.000.000 | 420.000.000 | 30.000.000 | 30,00% |
| | | | ២-គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | 5.000.000.000 | | | | | |
| | | | គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ១.០០០.០០០.០០០៛ | 1.000.000.000 | 1.000.000.000 | 330.000.000 | 670.000.000 | 55.000.000 | 33,00% |
| | | | ប្រេងឥន្ធនៈ ៤.០០០.០០០.០០០៛ | 4.000.000.000 | | | | | |
| | | | ៣-អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន CMAA | 13.900.000.000 | | | | | |
| | | | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន CMAA | 8.600.000.000 | 8.600.000.000 | 1.548.000.000 | 7.052.000.000 | 258.000.000 | 18,00% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | មជ្ឈមណ្ឌលបោសសំអាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ៣.៥០០.០០០.០០០៛ | 3.500.000.000 | | | | | |
| | | | អគ្គស្នងការដ្ឋាននគរបាលជាតិ ១.៨០០.០០០.០០០៛ | 1.800.000.000 | | | | | |
| | | | ៤-មជ្ឈមណ្ឌលសកម្មភាពកំចាត់មីន CMAC | 2.700.000.000 | | | | | |
| | | | ប្រតិបត្តិការ CMAC | 1.500.000.000 | 1.500.000.000 | 450.000.000 | 1.050.000.000 | 75.000.000 | 30,00% |
| | | | (CMAC) ក្រុមប្រឹក្សាភិបាល | 1.200.000.000 | 1.200.000.000 | 324.000.000 | 876.000.000 | 54.000.000 | 27,00% |
| | | | ៥-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | 1.700.000.000 | 1.700.000.000 | 420.000.000 | 1.280.000.000 | 70.000.000 | 24,71% |
| | | | ៦-គណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ( គជបអសប) | 2.400.000.000 | 2.400.000.000 | 435.000.000 | 1.965.000.000 | 72.500.000 | 18,13% |
| | | | ៧-គណៈកម្មាធិការជាតិប្រឆាំង អំពើភេរវកម្ម | 6.775.000.000 | 6.775.000.000 | 1.200.000.000 | 5.575.000.000 | 200.000.000 | 17,71% |
| | | | ៨-អង្គភាពពតិមាន និងប្រតិកម្មរហ័ស | 2.500.000.000 | 2.500.000.000 | 750.000.000 | 1.750.000.000 | 125.000.000 | 30,00% |
| | | 65025 | **ឧបត្ថម្ភកធនដល់អង្គការដែលមានលក្ខណៈវប្បធម៌** | 1.800.000.000 | 1.800.000.000 | 570.000.000 | 1.230.000.000 | 95.000.000 | 31,67% |
| | | | ១-ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | 700.000.000 | 700.000.000 | 210.000.000 | 490.000.000 | 35.000.000 | 30,00% |
| | | | ២-គណៈកម្មការជាតិយូណេស្កូកម្ពុជា | 300.000.000 | 300.000.000 | 90.000.000 | 210.000.000 | 15.000.000 | 30,00% |
| | | | ៣-គណៈកម្មាធិការជាតិបេតិកភ័ណ្ឌពិភពលោក | 800.000.000 | 800.000.000 | 270.000.000 | 530.000.000 | 45.000.000 | 33,75% |
| | | 65026 | **ឧបត្ថម្ភកធនដល់អង្គការដែលមានលក្ខណៈរដ្ឋបាល** | 2.600.000.000 | 2.600.000.000 | 792.000.000 | 1.808.000.000 | 132.000.000 | 30,46% |
| | | | ១-គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | 600.000.000 | 600.000.000 | 162.000.000 | 438.000.000 | 27.000.000 | 27,00% |
| | | | ២-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ | 1.500.000.000 | 1.500.000.000 | 450.000.000 | 1.050.000.000 | 75.000.000 | 30,00% |
| | | | ៣-គណៈវិស្វករកម្ពុជា | 500.000.000 | 500.000.000 | 180.000.000 | 320.000.000 | 30.000.000 | 36,00% |
